ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណ:កម្មាធិការជាតិរៀបចំការបោះឆ្នោត
អគ្គលេខាធិការដ្ឋាន
លេខ២០១ គ.ជ.ប/អគ្គ/ប្រ.ក.៣

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១៧

# សេចក្ដីប្រកាសព័ត៌មាន

នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ វេលាម៉ោង ៨:៣០នាទីព្រឹក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានសហការជាមួយទីភ្នាក់ងារប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) រៀបចំសិក្ខាសាលាសម្រាប់អ្នកសារព័ត៌មាន ស្ដីពីការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧ នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ ក្រោមអធិបតីភាពឯកឧត្តម **ហង្ស ពុទ្ធា** សមាជិក និងជាអ្នកនាំពាក្យ គ.ជ.ប ។

សិក្ខាសាលាធ្វើឡើងមានរយៈពេល ១ថ្ងៃ ដែលមានសិក្ខាកាមរួមមាន ៖ តំណាងក្រសួងមហាផ្ទៃ ក្រសួងព័ត៌មាន ស្ថានីយទូរទស្សន៍ចំនួន ៨ ស្ថានីយ៍វិទ្យុចំនួន ១១ គេហទំព័រចំនួន ៤ និងអង្គភាពសារព័ត៌មានចំនួន ៤ សរុបចំនួន ៥៥នាក់ ព្រមទាំងមានជំនាញការ JICA ជំនាញការសហភាពអឺរ៉ុប (EU) ជំនាញការ IFES និងជំនាញការ KOICA ចូលរួមជាភ្ញៀវកិត្តិយសផងដែរ។

ឯកឧត្តម **ហង្ស ពុទ្ធា** មានប្រសាសន៍ក្នុងពិធីបើកសិក្ខាសាលានេះថា អ្នកសារព័ត៌មាន គឺជាតួអង្គដ៏សំខាន់មួយដែលបានរួមចំណែកយ៉ាងសកម្មក្នុងការផ្សព្វផ្សាយព័ត៌មានដល់សាធារណជន និងអ្នកបោះឆ្នោត។ ឯកឧត្តមបន្តថា អ្នកសារព័ត៌មានត្រូវប្រកាន់ជំហរអព្យាក្រឹត មិនលំអៀងទៅរកគណបក្សនយោបាយណាមួយ ជាពិសេសជៀសវាងការផ្សព្វផ្សាយព័ត៌មានណាដែលនាំឱ្យមានការភាន់ច្រឡំដល់សាធារណជន និងនាំឱ្យមានការបាត់បង់ទំនុកចិត្តលើការបោះឆ្នោត។

មានមតិសំណេះសំណាលក្នុងសិក្ខាសាលានេះដែរលោកស្រី **អ៊ីម៉ៃ តាកាកុ** (Ms. IMAI TAKAKO) ទីប្រឹក្សាអង្គការ JICA ប្រចាំនៅ គ.ជ.ប បានលើកឡើងថា អ្នកសារព័ត៌មានជាភ្នាក់ងារដ៏សំខាន់ក្នុងការនាំសារអប់រំពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោតទៅកាន់ ប្រជាពលរដ្ឋ។ លោកស្រីបន្តថា ដើម្បីសរសេរអត្ថបទរបស់ខ្លួនបានច្បាស់លាស់ និងត្រឹមត្រូវ អ្នកព័ត៌មានត្រូវស្វែងយល់អំពីបទបញ្ញា និងនីតិវិធីនៃការចុះឈ្មោះបោះឆ្នោត។

សិក្ខាសាលានេះ គ្រូឧទ្ទេសបានធ្វើបទបង្ហាញលើប្រធានបទចំនួន ៦ រួមមាន ៖

- ភាពខុសគ្នារវាងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៦ និង២០១៧
- ការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧ តាមប្រព័ន្ធកុំព្យូទ័រ និងការបញ្ជូនទិន្នន័យមក គ.ជ.ប
- ការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការផ្ទៀងផ្ទាត់ទិន្នន័យអ្នកចុះឈ្មោះបោះឆ្នោតនៅ គ.ជ.ប
- ការអប់រំអ្នកបោះឆ្នោត

- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត និងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង
- តួនាទីរបស់អ្នកសារព័ត៌មានក្នុងការផ្សព្វផ្សាយអប់រំអ្នកចុះឈ្មោះបោះឆ្នោត។

ឯកឧត្តម **ទេព នីថា** អគ្គលេខាធិការ គ.ជ.ប ថ្លែងក្នុងកម្មវិធីបិទសិក្ខាសាលាថា នេះជាលើកទី៣ហើយដែល គ.ជ.ប សហការជាមួយអង្គការ JICA រៀបចំសិក្ខាសាលានេះឡើង។ ឯកឧត្តមបន្តថា សិក្ខាសាលានេះសំដៅដល់ការពង្រឹង និងបង្កើនការយល់ដឹងរបស់អ្នកសារព័ត៌មាន ឱ្យដឹងពីអ្វីដែលទាក់ទងនឹងដំណើរការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧ ដើម្បីផ្សព្វផ្សាយជូនដល់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត។ ឯកឧត្តមសង្ឃឹមថា អង្គភាពសារព័ត៌មាន អ្នកសារព័ត៌មាននឹងចូលរួមធ្វើការផ្សព្វផ្សាយតាមក្រមសីលធម៌ដែលបានកំណត់ដោយ គ.ជ.ប ៕